# ទំនប់វារីអគ្គិសនីសាយ៉ាប៊ូរីៈ របៀបដែលប្រទេសឡាវបានរំលោភកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥

ដោយ ឃើក ហើបើតសុន (Kirk Herbertson)

កាលពីថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១២ ប្រទេសឡាវបានចាប់ផ្តើមជាផ្លូវការនូវគម្រោងសាងសង់ទំនប់វារីអគ្គិសនីសាយ៉ាប៊ូរីពោរពេញដោយភាពចម្រូងចម្រាស ហើយដែលជាទំនប់វារីអគ្គិសនីដំបូងស្ថិតនៅតាមដងទន្លេធំនៃទន្លេមេគង្គក្រោម។ ដំណើរការនៃការសាងសង់នេះប្រព្រឹត្តទៅមិនបានរលូនទេ។ សកម្មភាពសាងសង់បានចាប់ផ្តើមមុនពេលប្រកាសជាផ្លូវការ ជិតពីរឆ្នាំ។ ប្រទេសវៀតណាម និងប្រទេសកម្ពុជាបានអំពាវនាវឲ្យពន្យារពេលសាងសង់ទំនប់នេះ ដោយសារប្រទេសទាំងពីរបារម្ភអំពីផលប៉ះពាល់អន្តរប្រទេស ដែលមិនទាន់បានដោះស្រាយនៅឡើយ។ ប្រទេសឡាវមិនដែលបានវិភាគល្អិតល្អន់អំពីផលប៉ះពាល់អន្តរប្រទេសឡើយ ហើយផ្ទុយទៅវិញបានអះអាងថា ទំនប់នេះធ្វើឲ្យមាននិរន្តរភាពបរិស្ថានទៅវិញទេ។ លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRC) បានជំទាស់នឹងការអះអាងរបស់ប្រទេសឡាវជាច្រើនលើក ច្រើនសារ ប៉ុន្តែការផ្តល់យោបល់របស់ខ្លួនមិនត្រូវបានគេយកចិត្តទុកដាក់ឡើយ។ ទោះបីជាដំណើរការនៃការសាងសង់ទំនប់នេះកំពុងប្រព្រឹត្តទៅក៏ដោយ ក៏គេមិនដឹងអំពីហានិភ័យនៃគម្រោងនេះឡើយ។

គម្រោងសាងសង់ទំនប់វារីអគ្គិសនីសាយ៉ាប៊ូរី គឺជាបទពិសោធយ៉ាងសំខាន់ដំបូងចំពោះកិច្ចព្រមព្រៀងទន្លេមេគង្គនេះ ដែលជាសន្ធិសញ្ញាចុះហត្ថលេខាកាលពីឆ្នាំ១៩៩៥ដោយប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម។ សន្ធិសញ្ញានេះមានគោលបំណងដើម្បីលើកកម្ពស់ឲ្យមានការប្រើប្រាស់ និងគ្រប់គ្រងអាងទន្លេមេគង្គនេះរួមគ្នា។ ប៉ុន្តែ ផ្ទុយពីកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលនៃប្រទេសជិតខាង ប្រទេសឡាវបានចាប់ផ្តើមអនុវត្តគម្រោងសាងសង់ទំនប់សាយ៉ាប៊ូរីនេះ ខណៈដែលប្រទេសកម្ពុជានិងប្រទេសវៀតណាមមានការព្រួយបារម្ភអំពីផលប៉ះពាល់អន្តរប្រទេសដោយសារគម្រោងនេះ។ ប្រទេសថៃមិនបានលើកឡើងច្រើនអំពីជម្លោះនេះទេ ប៉ុន្តែបានផ្តល់ហិរញ្ញប្បទានដោយស្ងាត់ៗសម្រាប់ការអនុវត្តគម្រោងនេះ ហើយបានព្រមព្រៀងទិញអគ្គិសនីពីទំនប់វារីអគ្គិសនីនេះទៀតផង។ រហូតមកដល់ខែវិច្ឆិកា ឆ្នាំ២០១២ ការអនុវត្តគម្រោងដោយប្រទេសឡាវ និងប្រទេសថៃបានដំណើរការទៅមុខ រហូតមក

ដល់ពេលនេះ ប្រទេសកម្ពុជានិងប្រទេសវៀតណាមនៅសល់ឥទ្ធិពលតិចតួចប៉ុណ្ណោះក្នុងការលើកឡើងអំពីក្ដីកង្វល់នេះ។

ប្រទេសឡាវបានអះអាងថា ការសាងសង់ទំនប់សាយ៉ាប៊ូរីនេះ អនុវត្តតាមកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ១៩៩៥។ មជ្ឈដ្ឋានមួយចំនួនទៀតបានចោទសួរអំពីការអះអាងនេះ។

នៅក្នុងរបាយការណ៍ថ្មីមួយ យើងបានពិនិត្យមើលអំពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងទន្លេមេគង្គនេះកាន់តែលម្អិត។ គ្រាន់តែមើលសើរៗ ខ្លឹមសារនៃកិច្ចព្រមព្រៀងនេះមិនច្បាស់លាស់ទាល់តែសោះ។ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីស្វែងរកការបញ្ជាក់ឲ្យបានច្បាស់លាស់ យើងពិនិត្យមើលលក្ខខណ្ឌនៃកិច្ចព្រមព្រៀងទន្លេមេគង្គទាំងស្រុងតែម្ដង។ ទន្ទឹមនេះ យើងពិនិត្យមើលៈ (i) របាយការណ៍ប្រវត្តិនៃការចរចា ដែលពិពណ៌នាអំពីអ្វីដែលភាគីទាំងនេះចង់បាននៅពេលពួកគេបានព្រាងកិច្ចព្រមព្រៀងនេះ និង (ii) ច្បាប់អន្តរជាតិដែលលើកឡើងអំពីអត្ថន័យនៃពាក្យពេចន៍ដែលត្រូវបានសរសេរនៅក្នុងកិច្ចព្រមព្រៀងនេះ។ តាមរយៈធ្វើដូចនេះ ធ្វើឲ្យយើងយល់អំពីកិច្ចព្រមព្រៀងទន្លេមេគង្គកាន់តែច្បាស់ជាងមុន។ យើងឃើញថា ប្រទេសឡាវបានបកស្រាយមិនត្រឹមត្រូវអំពីកិច្ចព្រមព្រៀងទន្លេមេគង្គនេះទេ ហើយមិនបានអនុវត្តតាមលក្ខខណ្ឌសំខាន់ៗមួយចំនួនឡើយ។

*របាយការណ៍ពេញលេញមានដូចខាងក្រោម ប៉ុន្តែលទ្ធផលពីការរកឃើញសំខាន់ៗត្រូវបានសង្ខេបនៅទីនេះ។*

## លក្ខខណ្ឌតម្រូវឲ្យប្រទេសឡាវស្វែងរកកិច្ចព្រមព្រៀងជាមួយប្រទេសជិតខាងខ្លួនមុនពេលចាប់ផ្ដើមគម្រោង។

ដើម្បីធ្វើឲ្យមានសតុល្យភាពរវាងសិទ្ធិរបស់ប្រទេសដែលស្ថិតនៅតាមទន្លេមេគង្គលើ និងទន្លេមេគង្គក្រោម កិច្ចព្រមព្រៀងទន្លេមេគង្គតម្រូវឲ្យរដ្ឋាភិបាលនៃប្រទេសទាំងបួនប្រឹងប្រែង "ដោយភាពស្មោះត្រង់" ដើម្បីឈានដល់ការព្រមព្រៀងថា តើគម្រោងនេះដំណើរទៅមុខឬទេ។ ផ្ទុយពីការប្រឹងប្រែងឈានដល់កិច្ចព្រមព្រៀងស្ដីពីទំនប់វារីអគ្គិសនីនេះ ប្រទេសឡាវបានអះអាងថា ខ្លួនគ្រាន់តែត្រូវពិចារណាអំពីការផ្ដល់យោបល់ពីសំណាក់រដ្ឋាភិបាលនៃប្រទេសដទៃ

តែប៉ុណ្ណោះ។ ប្រទេសឡាវមិនបានប្រឹងប្រែងសម្រុះសម្រួលអំពីជំហាររបស់ខ្លួន ឬសម្រេចឲ្យបាននូវដំណោះស្រាយដែលមានការព្រមព្រៀងគ្នាទៅវិញទៅមកឡើយ។

## ប្រទេសឡាវត្រូវតែផ្តល់ឱកាសឲ្យរដ្ឋាភិបាលនៃប្រទេសដទៃវាយតម្លៃផលប៉ះពាល់ដោយសារគម្រោង។

"ការពិគ្រោះយោបល់ជាមុន" របស់គណៈកម្មការទន្លេមេគង្គគឺជាដំណើរការដែលរដ្ឋាភិបាលនៃប្រទេសទាំងបួនព្យាយាមសម្រេចឲ្យបានកិច្ចព្រមព្រៀងមួយ។ គោលបំណងសំខាន់នៃការពិគ្រោះយោបល់ជាមុនគឺត្រូវផ្តល់ឱកាសឲ្យរដ្ឋាភិបាល វាយតម្លៃអំពីផលប៉ះពាល់អន្តរប្រទេសដោយសារគម្រោងនេះ។ ប៉ុន្តែ សម្រាប់ទំនប់សាយ៉ាប៊ូរីវិញ ប្រទេសឡាវមិនបានផ្តល់ឱកាសដល់រដ្ឋាភិបាលនៃប្រទេសជិតខាងដើម្បីវាយតម្លៃ អំពីផលប៉ះពាល់អន្តរប្រទេសដោយសារគម្រោងនេះទេ។ ជាពិសេស ប្រទេសឡាវមិនបានវាយតម្លៃផលប៉ះពាល់អន្តរប្រទេស មុនពេលចាប់ផ្តើមការពិគ្រោះយោបល់ជាមុន នៅខែកញ្ញាឆ្នាំ២០១០នោះឡើយ។

## ប្រទេសឡាវមិនត្រូវបានអនុញ្ញាតឲ្យអនុវត្តគម្រោងនេះទេ នៅពេលដែលការពិគ្រោះយោបល់កំពុងតែដំណើរការនៅឡើយ។

ច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងទន្លេមេគង្គហាមរដ្ឋាភិបាលនៃប្រទេសទាំងនេះមិនឲ្យអនុវត្តគម្រោងនេះឡើយ ខណៈដែលរដ្ឋាភិបាលកំពុងពិភាក្សាអំពីបញ្ហានេះនៅឡើយនោះ។ នេះគឺជាកាតព្វកិច្ចដើម្បីធ្វើការចរចា "ដោយស្មោះត្រង់"។ ប្រទេសឡាវ និងក្រុមហ៊ុនអភិវឌ្ឍន៍Ch. Karnchang បានចាប់ផ្តើមអនុវត្តគម្រោងសាងសង់ទំនប់សាយ៉ាប៊ូរីនេះកាលពីចុងឆ្នាំ២០១០ មុនពេលរដ្ឋាភិបាលនៃប្រទេសស្ថិតនៅតាមដងទន្លេមេគង្គ ជួបប្រជុំពិភាក្សាគ្នាអំពីគម្រោងនេះ។ ក្រោយមក ប្រទេសឡាវបានអះអាងដោយមិនត្រឹមត្រូវថា "ការងារត្រៀមខ្លួន" នេះត្រូវបានអនុញ្ញាតក្រោមកិច្ចព្រមព្រៀងទន្លេមេគង្គ ខណៈដែលការពិគ្រោះយោបល់កំពុងតែដំណើរការនោះ។

## លក្ខខណ្ឌតម្រូវឲ្យប្រទេសឡាវសិក្សាអំពីផលប៉ះពាល់អន្តរប្រទេសដោយសារគម្រោងនេះ មុនពេលធ្វើការពិគ្រោះយោបល់

តាមច្បាប់អន្តរជាតិ ដាក់លក្ខខណ្ឌឲ្យរដ្ឋាភិបាលនៃប្រទេសទាំងនេះ ទប់ស្កាត់កុំឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រទេសដទៃ ដែលក្នុងនោះកំណត់ពេលវេលាដោយឡែកគ្រប់គ្រាន់សម្រាប់វាយតម្លៃអំពីផលប៉ះពាល់អន្តរប្រទេសដោយសារគម្រោងនេះ។ ក្រោយពីខកខានមិនបានធ្វើការវាយតម្លៃផលប៉ះពាល់អន្តរប្រទេស ដោយសារទំនប់សាយ៉ាប៊ូរីកាលពីឆ្នាំ២០១០ ប្រទេសឡាវបានបដិសេធមិនព្រមពន្យារពេលអនុវត្តគម្រោងនេះឡើយ បន្ទាប់ពីប្រទេសកម្ពុជា និងប្រទេសវៀតណាមបានស្នើឲ្យធ្វើការសិក្សាអំពីផលប៉ះពាល់ទាំងនេះអំឡុងពេលពិគ្រោះយោបល់ជាមុន។ ផ្ទុយទៅវិញ ប្រទេសឡាវបានអះអាងថា បច្ចេកវិទ្យាដែលមិនទាន់បានធ្វើការសាកល្បងដែលស្នើឡើងដោយក្រុមហ៊ុនពិគ្រោះយោបល់ឈ្មោះ Pöyry នោះគឺគ្រប់គ្រាន់ដើម្បីកាត់បន្ថយផលប៉ះពាល់ហើយ។

## ប្រទេសកម្ពុជា វៀតណាម និងប្រទេសថៃមានសិទ្ធិពន្យារពេលការពិគ្រោះយោបល់ជាមុនបាន

ពេលវេលាកំណត់សម្រាប់ការពិគ្រោះយោបល់ជាមុនគឺប្រាំមួយខែ ប៉ុន្តែយោងតាមច្បាប់អន្តរជាតិរដ្ឋាភិបាលនៃប្រទេសស្ថិតនៅតាមទន្លេមេគង្គក្រោមមានសិទ្ធិពន្យារពេល។ ប្រទេសឡាវអះអាងថា ការពិគ្រោះយោបល់ជាមុនអំពីទំនប់សាយ៉ាប៊ូរីបានបញ្ចប់ដោយស្វ័យប្រវត្តិក្រោយពីរយៈពេលប្រាំមួយខែ។ អំឡុងពេលប្រាំមួយខែដំបូងនេះ ប្រទេសឡាវខកខានមិនបានផ្តល់ព័ត៌មាន ដែលរដ្ឋាភិបាលនៃប្រទេសដទៃត្រូវការដើម្បីធ្វើការវាយតម្លៃអំពីផលប៉ះពាល់ដោយសារគម្រោងនេះឡើយ។ បញ្ហានេះបានធ្វើឲ្យប៉ះពាល់ដល់គោលបំណងសំខាន់ៗនៃការពិគ្រោះយោបល់ជាមុននេះ។ ប្រទេសឡាវក៏បានចាប់ផ្តើមអនុវត្តគម្រោងក្នុងអំឡុងពេលដំបូងនេះដែរ។

## ប្រទេសកម្ពុជា ថៃ និងប្រទេសវៀតណាមមានសិទ្ធិទាមទារសំណងសម្រាប់ផលប៉ះពាល់ណាមួយដែលបានកើតឡើង។

តាមច្បាប់អន្តរជាតិ ប្រទេសឡាវមានកាតព្វកិច្ច ផ្អាកគម្រោងនេះភ្លាមៗ ប្រសិនបើគម្រោងនេះប៉ះពាល់ដល់ប្រទេសជិតខាង។ រដ្ឋាភិបាលនៃប្រទេសនៅតាមទន្លេមេគង្គក្រោម មានប្រទេសកម្ពុជា ថៃនិងប្រទេសវៀតណាមជាដើមអាចទាមទាររកសំណងចំពោះផលប៉ះពាល់ណាមួយដោយសារទំនប់នេះ។ ប៉ុន្តែ ប្រទេសកម្ពុជា ថៃ និងប្រទេសវៀតណាម មានការលំបាកក្នុងការ

ទាមទាររកសំណងណាស់ ពីព្រោះមិនមានទិន្នន័យមូលដ្ឋានគ្រប់គ្រាន់នៅពេលនេះដើម្បីថ្លឹងថ្លែងថា តើទំនប់សាយ៉ាប៊ូរីនេះនឹងធ្វើឲ្យផ្លាស់ប្តូរទឹកទន្លេមេគង្គដូចម្តេចនោះ។ ឥឡូវនេះប្រទេសទាំងបី ប្រឈមការលំបាកក្នុងការតាមដានយ៉ាងជិតដល់អំពីផលប៉ះពាល់ដោយសារទំនប់នេះណាស់។

ទំនប់សាយ៉ាប៊ូរីនេះជាដើមចមដ៏គ្រោះថ្នាក់ ដែលអាចបង្កផលប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការនាពេលអនាគត។ នៅឆ្នាំ២០១៣នេះ ការងារសាងសង់អាចបន្តទំនប់វារីអគ្គិសនីពីរទៀតនៅតាមទន្លេមេគង្គគឺទំនប់ដូនសាហុង និងទំនប់បាក់បេង។ ដរាបណាគ្មានកំណែទម្រង់ឲ្យបានឆាប់ទេ នោះការខ្វែងគំនិតគ្នាជុំវិញការសាងសង់ទំនប់វារីអគ្គិសនីនៅតាមទន្លេមេគង្គនេះអាចឈានដល់ជម្លោះធ្ងន់ធ្ងរដោយផលវិបាកសេដ្ឋកិច្ច និងនយោបាយជាមិនខានឡើយ។

សូមអានរបាយការណ៍ពេញលេញជាភាសាអង់គ្លេសតាមអាសយដ្ឋានៈ
http://www.internationalrivers.org/files/attached-files/intl_rivers_analysis_of_mekong_agreement_january_2013.pdf

## ព័ត៌មានបន្ថែមៈ

- សូមចូលទៅមើលទំព័របណ្តាញរបស់យើង Xayaburi Dam Webpage។